

# ពន្លឺព្រះចន្ទ

Belgian Development Cooperation null

null

letsreadasia.org



ពាក្យថ្មីនៅក្នុងសៀវភៅនេះ៖ ក្រោម ខានស្អែក ចម្ការ ចង្កៀង ឆ្ងាយ នឹង ប្អូន បី ព្រះចន្ទ ភ្លើង



កូនៗ ថ្ងៃខានស្អែកពុកត្រូវទៅឆ្ងាយ ។
ពុកទៅណា? ពុកទៅចម្ការ ។



ពុកកុំទៅអី ។ ខ្ញុំមិនឱ្យពុកទៅទេ ។ ទេ!
ពុកត្រូវតែទៅ ។



ពុក! ពុកនៅឯណា? ចែម ពុកនៅក្រោមផ្ទះ ។



ចែម! ឃើញភ្លើងចង្កៀងនេះទេ? ពេល
ពុកនៅក្រោមផ្ទះ ក៏ឃើញភ្លើង ចង្កៀង
នេះដែរ ។



កូនៗ ថ្ងៃស្អែកពុកត្រូវទៅឆ្ងាយ ។ ពុក
ទៅឆ្ងាយអត់ឃើញភ្លើងចង្កៀងទេ ។



ចែម! កូនមើលទៅព្រះចន្ទនោះ ។ ពុក
ទៅឆ្ងាយក៏មើលឃើញព្រះចន្ទ នោះដែរ
។



តារាមើលប្អូនៗផង ។ បីថ្ងៃទៀត ពុក
នឹងមកវិញ ។



Brought to you by

The Asia Foundation

Let's Read! is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia. booksforasia.org

To read more books like this and get further information about this book, visit letsreadasia.org

Original Story
ពន្លឺព្រះចន្ទ, author: Belgian Development Cooperation null. illustrator: by null. Published by Ministry of Education, Youth, and Sports of Cambodia, © Ministry of Education, Youth, and Sports of Cambodia.

Translations: © The Asia Foundation, 2018.